**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ: ០២០/២៤ ក.ប/ស.ជ.ណា.ខ.ល

# សេចក្តីជូនដំណឹង

## ស្តីពី

## ការចុះបញ្ជីសមាជិក ប.ស.ស. ជាបុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. តាមរយៈកម្មវិធីទូរស័ព្ទដៃ "NSSF MEMBER APP"

ដើម្បីសម្រួលដល់ការងារចុះបញ្ជីជាសមាជិក ប.ស.ស. ឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងដាក់ឱ្យដំណើរការការចុះបញ្ជីសមាជិក ប.ស.ស. ជាបុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. តាមរយៈកម្មវិធីទូរស័ព្ទដៃ "NSSF MEMBER APP" ចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤ នេះតទៅ ដោយសមាជិក ប.ស.ស. និងសាធារណជនទាំងអស់ អាចទាញយក និងដំឡើងកម្មវិធីនេះ ព្រមទាំងរបៀបប្រើប្រាស់តាមតំណភ្ជាប់ដូចខាងក្រោម៖

GET IT ON Google Play

Download on the App Store

របៀបប្រើប្រាស់

ជាមួយគ្នានេះ ក្រសួងក៏មានក្រុមការងារឆ្លើយតប និងផ្តល់ព័ត៌មានផ្សេងៗតាមរយៈប្រព័ន្ធ Hotline លេខ "១២៨៦" ឬ "១២៩៧" ដែលធ្វើការ ២៤ម៉ោងក្នុងមួយថ្ងៃ និង ៧ថ្ងៃក្នុងមួយសប្តាហ៍ ឬក្រុមតេឡេក្រាមផ្លូវការ "បេឡាជាតិសន្តិសុខសង្គម_Chat" របស់ ប.ស.ស. ដែលមានតំណភ្ជាប់ https://t.me/nssfcambodia_Chat ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសមាជិក ប.ស.ស. និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែសីហា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩